# ស្ថានភាពអតិផរណានៅខែមីនា ឆ្នាំ២០១៩

## ក. អតិផរណាក្នុងប្រទេស

តាមប្រភពទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា នៅខែមីនា ឆ្នាំ២០១៩នេះ ជារួម សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខនៅរាជធានីភ្នំពេញ ***មានការកើនឡើង ០,៣% បើធៀបនឹងខែមុន និង ២,២% បើធៀបនឹងខែមីនាឆ្នាំមុន។*** សន្ទស្សន៍ថ្លៃក្រុមទំនិញស្ទើរតែទាំងអស់ មានការប្រែប្រួលបន្តិចបន្តួច ជាពិសេសក្រុមមុខទំនិញអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង និងក្រុមមុខទំនិញផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត បើធៀបនឹងខែកុម្ភៈកន្លងទៅ។ ប៉ុន្តែបើធៀបនឹងខែមីនា ឆ្នាំ២០១៨ សង្កេតឃើញថា សន្ទស្សន៍ថ្លៃទំនិញភាគច្រើនមានការកើនឡើង ជាពិសេសសន្ទស្សន៍ថ្លៃក្រុមទំនិញភោជនីយដ្ឋាន (កើន ៨,២%), ក្រុមទំនិញភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ (កើន ៦,៧%), និងក្រុមទំនិញសម្លៀកបំពាក់និងស្បែកជើង (កើន ៣,៦%)។

***ក្នុងត្រីមាសទី១ ដើមឆ្នាំ២០១៩នេះ សន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម មានកំណើន ១,៩% ជាមធ្យម ទាបជាងអត្រាកំណើនជាមធ្យមក្នុងរយៈពេលដូចគ្នាឆ្នាំ២០១៨ ដែលមានអត្រា ២,២%។*** តាមរយៈទិន្នន័យដែលទទួលបាន បង្ហាញថា សន្ទស្សន៍ថ្លៃក្រុមទំនិញមានកំណើនខ្លាំងជាងគេ រួមមាន **ក្រុមទំនិញភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់មានអត្រាកំណើនជាមធ្យម ៦,៥% ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ (០,១% ក្នុងត្រីមាសទី១ ឆ្នាំ២០១៨)។ កំណើននេះ គឺដោយសារថ្លៃថ្នាំជក់មានការកើនឡើងនៅលើទីផ្សារ (*កំណើនប្រមាណ ២ ៨០០រៀល/១គីឡូក្រាម*)**។ ជាក់ស្តែង ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ ថ្នាំជក់ខ្លាំង មានតម្លៃមធ្យម ២២ ៩០០រៀល/១គីឡូក្រាម ខ្ពស់ជាងតម្លៃមធ្យមក្នុងរយៈពេលដូចគ្នាឆ្នាំមុន (តម្លៃត្រឹមតែ ២០ ១០០ រៀល/១គីឡូក្រាម)។ **ចំណែកឯ ក្រុមទំនិញការដឹកជញ្ជូនធ្លាក់ចុះជាមធ្យម ៣,៨% ក្នុងត្រីមាសទី១ ឆ្នាំ២០១៩ (កំណើនជាមធ្យម ៣,១% ក្នុង ត្រីមាសទី១ ឆ្នាំ២០១៨) ដោយសារការធ្លាក់ចុះនៃថ្លៃប្រេងសាំងធម្មតា និងម៉ាស៊ូត។** យោងតាមទិន្នន័យរបស់ក្រសួងពាណិជ្ជកម្ម ក្នុងត្រីមាសទី១ ឆ្នាំ២០១៩នេះ ប្រេងសាំងធម្មតា និងម៉ាស៊ូតថ្លៃជាមធ្យម ៣ ៤៥០រៀល/ លីត្រ និង ៣ ៤៣០រៀល/ លីត្រ រៀងគ្នា ទាបជាងថ្លៃមធ្យមក្នុងរយៈពេលដូចគ្នាឆ្នាំមុន ៣ ៨៨០រៀល/ លីត្រ និង ៣ ៦៦០ រៀល/ លីត្រ។ ការធ្លាក់ចុះថ្លៃនេះ គឺស្របគ្នាទៅនឹងការធ្លាក់ចុះថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិផងដែរ។

***តាមការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ២០១៩ អត្រាអតិផរណាឆ្នាំលើឆ្នាំ (year on year) និងអតិផរណាមធ្យមប្រចាំឆ្នាំ (year average) អាចមានអត្រា ៣,៤% និង ២,៥% រៀងគ្នា។*** នៅឆ្នាំ២០១៩នេះ ស្ថានភាពអតិផរណានៅតែស្ថិតក្នុងរង្វង់ក្រោម ៥% ដោយសារតែ i) ស្ថិរភាពថ្លៃមុខទំនិញប្រើប្រាស់ (consumption goods) ជាពិសេស ម្ហូបអាហារនៅលើទីផ្សារ, ii) ការឧបត្ថម្ភធនលើប្រេងឥន្ធនៈពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរក្សាស្ថិរភាពថ្លៃប្រេងសាំង និង iii) ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលធ្វើឱ្យកំណើនអតិផរណាស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ។

| តារាង ១ ÷ ការប្រែប្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ ក្រុម មានដូចខាងក្រោម÷ | | |
|---|---|---|
| | ធៀបនឹងខែមុន (%) | ធៀបនឹងឆ្នាំមុន (%) |
| **មុខទំនិញគ្រប់មុខ** | **+០,៣** | **+២,២** |
| ១-អាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | -០,១ | +១,៩ |
| ២-ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +០,១ | +៦,៧ |
| ៣-សម្លៀកបំពាក់ និងស្បែកជើង | +០,២ | +៣,៦ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | +០,៦ | +១,៩ |
| ៥-គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់ និងការថែទាំ | -០,២ | +១,៧ |
| ៦-សុខាភិបាល | -០,២ | +១,៩ |
| ៧-ការដឹកជញ្ជូន | +២,០ | -១,៨ |
| ៨-គមនាគមន៍ | -០,២ | -០,៤ |
| ៩-ការកំសាន្ត និងវប្បធម៌ | -០,៣ | +០,៨ |
| ១០-ការសិក្សា | ០,០ | +០,៤ |
| ១១-ភោជនីយដ្ឋាន | +១,២ | +៨,២ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -០,១ | +១,៤ |

| តារាង ២ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៩ | | | ២០១៩ | | |
| | មករា | កុម្ភៈ | មីនា | មករា | កុម្ភៈ | មីនា |
| អង្ករ | +០,២ | +០,៦ | ០,០ | +២,៦ | +២,៩ | +២,៧ |
| សាច់គោ | +០,៤ | +០,២ | ០,០ | +២,១ | +១,៦ | +១,៧ |
| សាច់មាន់ | +០,៥ | ០,០ | +០,៥ | +៤,០ | +២,៩ | +៤,២ |
| សាច់ទា | +០,៦ | +០,៦ | ០,០ | +២,២ | +៣,០ | +៣,១ |
| សាច់ជ្រូក | +០,៧ | +០,៦ | -០,៦ | +១,៧ | +២,០ | +០,៨ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,២ | +០,២ | ០,០ | +២,៦ | +២,៤ | +២,២ |
| ក្នុងនោះត្រីស្រស់ | ០,០ | ០,០ | ០,០ | +២,០ | +១,៦ | +១,៣ |
| ផ្លែឈើ | -០,៧ | +១,៣ | +០,២ | +១,៧ | +១,២ | +១,៤ |
| ផ្លែឈើស្រស់ | -០,៦ | +១,៤ | +០,៤ | +១,៦ | +១,២ | +១,៦ |
| បន្លែ | -១,០ | +១,៤ | -០,៦ | +២,៧ | +៣,៩ | +៣,០ |
| បន្លែជាស្លឹក | -១,១ | +១,៤ | -០,៤ | +៥,១ | +៦,៥ | +៥,២ |
| បន្លែជាផ្លែ | -១,៥ | +២,២ | -១,១ | +២,៣ | +៣,៨ | +២,២ |

## ២. អតិផរណាប្រចាំឆ្នាំតាមបណ្តាប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | |
|---|---|---|---|---|
| ប្រទេស | ២០១៨ | ២០១៩ | | |
| | ធ្នូ | មករា | កុម្ភៈ | មីនា |
| ប្រទេសកម្ពុជា | +១,៦ | +១,៥ | +២,០ | +២,២ |
| ប្រទេសវៀតណាម | +៣,០ | +២,៦ | +២,៦ | +២,៧ |
| ប្រទេសថៃ | +០,៤ | +០,៣ | +០,៧ | +១,២ |
| ប្រទេសម៉ាឡេស៊ី | +០,២ | -០,៧ | -០.៤ | +០,២ |
| ប្រទេសឥណ្ឌូនេស៊ី | +៣,១ | +២,៨ | +២,៦ | +២,៥ |
| ប្រទេសហ្វីលីពីន | +៥,១ | +៤,៤ | +៣,៨ | +៣,៣ |
| ប្រទេសចិន | +១,៩ | +១,៧ | +១,៥ | +២,៣ |
| ប្រទេសកូរ៉េខាងត្បូង | +១,៣ | +០,៨ | +០,៥ | +០,៤ |
| ប្រទេសជប៉ុន | +០,៣ | +០,២ | +០,២ | +០,៥ |

ប្រភពទិន្នន័យ
(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)
(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបតំរូវចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមភាគធរណីមាត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

**រៀបចំនិងធ្វើចំណោលដោយ**

**នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច**

**អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧  ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*